17-8

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ឯករាជ្យ - សន្តិភាព - សេរីភាព - សុភមង្គល

ក្រុមប្រឹក្សារដ្ឋមន្ត្រី

លេខ : ២៤៨ សសរ.

ភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨

# សេចក្តីសំរេច

## ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ ស្តីពីអង្គការរៀបចំ និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យច្បាប់លេខ ០៣ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨[illegible]
- បានឃើញក្រឹត្យ - ច្បាប់លេខ ១៨ ក្រ.ប ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការបង្កើតទីស្តីការ រដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ សង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីតួនាទីភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងយុទ្ធជនពិការ សង្គមកិច្ច
- បានឃើញសេចក្តីសំរេចលេខ ០១សសរ.៨៣ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ១៩៨៣ ស្តីពីគោលនយោបាយចំពោះការធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មករ
- តាមសំណើរដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ សង្គមកិច្ច.

## សំរេច

ប្រការ១: - កម្មាភិបាល បុគ្គលិក កម្មករក្នុងក្របខ័ណ្ឌរបស់រដ្ឋទាំងពីរភេទ ត្រូវបានទទួលគោលនយោបាយធានារ៉ាប់រងសង្គម តាមករណីដូចខាងក្រោម :

១- មានជម្ងឺ

២- គ្រោះថ្នាក់ការងារ ឬ របួសកម្ម

៣- សំរាលកូន

៤- មរណភាព

៥- ជួបការលំបាកខ្លាំង ។

ដោយឡែក ចំពោះនិវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម ត្រូវបានទទួលគោលនយោបាយធានារ៉ាប់រងសង្គម តាមករណី ៣ យ៉ាង :

១- មានជម្ងឺ

២- មរណភាព

ប្រការ ២ :- ករណីមានជម្ងឺ :

១- កម្មាភិបាល បុគ្គលិក កម្មករ និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម ដែលមានជម្ងឺ មានសិទ្ធិទៅពិនិត្យជម្ងឺនៅមន្ទីរពេទ្យព្យាបាលសាធារណៈ ដោយឥតគិតថ្លៃ ។

២- កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ក្នុងរយៈពេលព្យាបាលជម្ងឺ នៅមានសិទ្ធិបើកប្រាក់បៀវត្សរ៍ប្រចាំខែពេញលេញ ដោយមានប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចកាលកំពុងបំពេញភារកិច្ចដដែល ហើយត្រូវបង់ថ្លៃម្ហូបអាហារដែលមន្ទីរពេទ្យបានកំណត់ ។ ផុតកំណត់ ៣ ខែ ចាប់ពីខែទី ៤ រហូតដល់ខែទី ១២ សាមីជនត្រូវទទួលប្រាក់បៀវត្សរ៍ប្រចាំខែ ៩០ ភាគរយ ដោយមានប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ ប្រាក់ឧបត្ថម្ភផ្សេងៗ និង មានសិទ្ធិទិញស្បៀង និង របបផ្គត់ផ្គង់ដដែល ។ ផុតកំណត់ សាមីជនត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ១៥០ ភសរ ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ ១៩៨៥ ស្ដីពីរបបសោធននិវត្ត និង សោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ។

៣- កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ត្រូវបានទទួលប្រាក់បៀវត្សរ៍ប្រចាំខែពេញលេញ ទាំងប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចកាលកំពុងបំពេញភារកិច្ចដដែល ក្នុងរយៈពេល ១៨ ខែ ។ ផុតកំណត់រយៈពេលនេះ បើជម្ងឺនៅតែមិនទាន់ជាសះស្បើយ គឺត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពពលកម្ម ។

ប្រការ ៣ :- ករណីគ្រោះថ្នាក់ការងារ ឬ បេសកកម្ម :

១- កម្មាភិបាល បុគ្គលិក កម្មករ ដែលមានគ្រោះថ្នាក់ការងារ ឬ បំពេញបេសកកម្ម ត្រូវបានការជួយសង្គ្រោះជាបន្ទាន់ និង ព្យាបាលរហូតដល់ពេលជាសះស្បើយ ។ ចំណាយលើការសង្គ្រោះបន្ទាន់ និង ចំណាយទិញឱសថព្យាបាល រាប់ទាំងការព្យាបាលសាជាថ្មី ត្រូវបានសាមីអង្គភាពជួយឧបត្ថម្ភ ។ សាមីជននៅមានសិទ្ធិទទួលប្រាក់បៀវត្សរ៍ប្រចាំខែពេញលេញដដែល ទាំងប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ ឬ ប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងរយៈពេលព្យាបាល ។

២- ក្រោយពីបានព្យាបាលជាសះស្បើយហើយ សាមីជនត្រូវទទួលភារកិច្ចបំពេញការងារនៅកន្លែងដែលធ្លាប់ធ្វើពីមុន ។ ក្នុងករណីដែលត្រូវអោយមានការផ្លាស់ប្ដូរកន្លែងធ្វើការសមស្របទៅតាមស្ថានភាពសុខភាព និង សមត្ថភាពវិជ្ជាជីវៈ សាមីជនត្រូវបានទទួលប្រាក់បៀវត្សរ៍ប្រចាំខែ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ទៅតាមភារកិច្ចថ្មីដែលបានប្រគល់អោយ ។

៣- ក្រោយពីបានជាពេញលេញហើយ សាមីជនម្នាក់ៗ ត្រូវបានក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាលខេត្ត-ក្រុង ពិនិត្យវាយតម្លៃសុខភាព តាមកម្រិតមុខរបួសជាប្រភេទថ្នាក់ ដូចមានចែងក្នុងប្រការ ៣ កថាខណ្ឌ ២ ចំណុច ក នៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៧២ សសរ. ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៨៦ ស្ដីពីគោលនយោបាយចំពោះជនពិការ មរណៈ ។ សាមីជនម្នាក់ៗ ត្រូវបានរដ្ឋអនុញ្ញាតិអោយឈប់សំរាកបំប៉នសុខភាព និង ផ្ដល់របបគោលនយោបាយ ដូចខាងក្រោមនេះ :-

ក- មានសិទ្ធិឈប់សំរាក តាមកម្រិតមុខរបួស-ជម្ងឺ :

- ថ្នាក់ទី ១ ចំនួន ៦០ ថ្ងៃ
- ថ្នាក់ទី ២ ចំនួន ៤៥ ថ្ងៃ

(handwritten margin notes:) ចស = 90% ប + ត + 63/-ប...)
ចស (ប្រាក់ការ/ប្រចាំខែ)
ប (ប្រាក់ បៀវត្សរ៍/ប្រចាំខែ)
ត (ប្រាក់តំបន់ ...)
៩០/...

- ថ្នាក់ទី ៣ ចំនួន ៣០ ថ្ងៃ
- ថ្នាក់ទី ៤ ចំនួន ១៥ ថ្ងៃ ។

ក្នុងរយៈពេលឈប់សំរាកបំប៉នសុខភាពនេះ សាមីជនម្នាក់ៗមានសិទ្ធិទទួលប្រាក់បៀវត្សរ៍ប្រចាំខែ រួមទាំងប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចពេលកំពុងបំពេញការងារដែរ ។

ខ - ត្រូវបានទទួលប្រាក់ជំនួយមុខរបួស - ជម្ងឺចំនួនមួយលើក ដោយគិតតាមប្រាក់បៀវត្សរ៍ប្រចាំខែ ប្រាក់តំបន់ ប្រាក់ឧបត្ថម្ភគ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ។

| បាត់បង់កំរិតពលកម្ម | ប្រាក់ជំនួយមុខរបួស - ជម្ងឺ |
|---|---|
| ថ្នាក់ទី ១ | ៤ ខែ |
| ថ្នាក់ទី ២ | ៣ ខែ |
| ថ្នាក់ទី ៣ | ២ ខែ |
| ថ្នាក់ទី ៤ | ១ ខែ |

បើបាត់បង់សមត្ថភាពពលកម្មកំរិតថ្នាក់ទី ១ និង ទី ២ ត្រូវបានទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ។

បើបាត់បង់សមត្ថភាពពលកម្មកំរិតថ្នាក់ទី ៣ និង ទី ៤ អាចបន្តការងារទៅទៀតបាន ត្រូវបានផ្តល់ប្រាក់ជំនួយមុខរបួស - ជម្ងឺ បន្ថែមជារៀងរាល់ខែ ដោយគិតតាមសមាមាត្រនៃប្រាក់បៀវត្សរ៍ប្រចាំខែ ដូចខាងក្រោម :

| បាត់បង់កំរិតពលកម្ម | ប្រាក់ជំនួយមុខរបួស - ជម្ងឺ |
|---|---|
| ថ្នាក់ទី ៣ | ១៥ ភាគរយ |
| ថ្នាក់ទី ៤ | ១០ ភាគរយ |

ករណីបាត់បង់សមត្ថភាពពលកម្ម មិនអាចបន្តការងារទៅទៀតបាន ត្រូវបានក្រសួងសុខាភិបាល ឬ មន្ទីរសុខាភិបាល ខេត្ត - ក្រុងនាំទៅពិនិត្យសុខភាពជាថ្មី ដើម្បីកំណត់កំរិតថ្នាក់ទទួលរបបសោធនបាត់បង់សមត្ថភាពពលកម្មអតិបរិមា ។ បើចាស់ជរាគ្រប់លក្ខណៈសម្បត្តិអាចនិវត្តន៍ គឺត្រូវបានទទួលរបបសោធនអតិបរមា ។

**ប្រការ ៤ :- ករណីសំរាលកូន :**

១- កម្មាភិបាល បុគ្គលិក កម្មករនារី មានសិទ្ធិចូលទៅពិគ្រោះ និង សំរាលកូននៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈ ដោយឥតគិតថ្លៃ ។

២- ក្រោយពេលសំរាល រាប់ទាំងការរលូតកូនផង សាមីជនត្រូវបានទទួលប្រាក់ឧបត្ថម្ភចំនួន ២០០ រៀល ។ ចំនួនប្រាក់នេះនឹងកើនទ្វេរឡើងចំពោះអ្នកដែលធ្វើការក្នុងកន្លែងការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ។ ពេលសំរាលកូនភ្លោះ ប្រាក់ឧបត្ថម្ភនោះនឹងកើនឡើងជាទ្វេគុណ ឬ ត្រីគុណ តាមចំនួនកូន ។

ប.: ប្រាក់បៀវត្ស
ត.: ប្រាក់តំបន់ គិតលើ ប
15% ប: ប្រាក់ជំនួយមុខរបួស
ជាន់ទី 3 គិតលើ ប

ប សរុប = ប + ត + 15% ប + ប x 7 + ... + ... + ... + ... ---

៣ - ក្នុងរយៈពេលសំរាកសំរាលកូន ស្រ្តីមាតាកំពុងតែជាមន្រ្តីរាជការ ការមិនត្រូវបាន ទទួលប្រាក់បៀវត្សរ៍ប្រចាំខែពេញលេញ ដូចពេលកំពុងបំពេញការងារដែរ ។

៤ - ចាប់ពីថ្ងៃសំរាលកូនដល់ ១២ ខែពេញ បើសិនជាមានការបញ្ជាក់ពីមន្ទីរពេទ្យថា ម្តាយទារកពុំមានទឹកដោះ ឬ មានជម្ងឺ មិនអាចបំបៅទារកបានទេ នារីទាំងនោះមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភចំនួន ១៥០ រៀលក្នុងមួយខែ ក្នុងទារកម្នាក់ ។

៥ - រយៈពេល ១២ ខែ ចាប់ពីថ្ងៃសំរាល មាតាទាំងនោះមានសិទ្ធិឈប់សំរាកថែម ១ ម៉ោងក្នុងមួយថ្ងៃ សំរាប់បំបៅកូន ។

ប្រការ ៥ :- ករណីមរណៈភាព :

ក - មរណៈភាពដោយជម្ងឺ :

ក១ - កម្មាភិបាល បុគ្គលិក កម្មករ ទទួលមរណៈភាពដោយជម្ងឺនៅមន្ទីរពេទ្យ ឬ នៅផ្ទះ រដ្ឋឧបត្ថម្ភប្រាក់ចំនួន ១.៨០០ រៀល សំរាប់ធ្វើបុណ្យតាមប្រពៃណី ។ ចំពោះនិវត្តជន និង ជនទុព្វលភាពពលកម្ម ក៏ត្រូវបានទទួលរបបដោយឡែក ដូចខាងលើនេះដែរ ។

ក២ - គ្រួសារសព ត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹងប្រាក់បៀវត្សរ៍ប្រចាំខែដោយគិតប្រាក់គោល ប្រាក់បំណាច់គ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗចំនួន ៦ ខែ ។ ចំពោះនិវត្តជន និង ជនទុព្វលភាពពលកម្ម គ្រួសារបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹងប្រាក់សោធនប្រចាំខែចំនួន ៦ ខែ ។

ក៣ - ចំពោះកូនចៅរបស់សព ក្នុងករណីដែលឪពុក ឬ ម្តាយនៅរស់ ប៉ុន្តែមិនមែនជាកម្មាភិបាល បុគ្គលិក កម្មករ និង ក្នុងករណីដែលគ្មានឪពុក ឬ ម្តាយ ដែលមានទីពឹង នោះត្រូវទទួលប្រាក់ឧបត្ថម្ភ និង មានសិទ្ធិទិញរបបផ្គត់ផ្គង់របស់រដ្ឋ ដូចកូនកម្មាភិបាល បុគ្គលិក កម្មកររដ្ឋដែលកំពុងបំពេញការងារទាំងអស់ ចំពោះអង្ករមានសិទ្ធិទិញ ១៥ គីឡូក្រាមក្នុងមួយខែ រៀងរាល់ខែ ។ ការអនុវត្តត្រូវបានកំណត់ដូចខាងក្រោម :

- រហូតដល់អាយុ ១៨ ឆ្នាំ :
- ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ រហូតដល់ពេលរៀន បើកំពុងបន្តការសិក្សា ហើយគ្មានទទួលអាហាររូបករណ៍ ។
- បើពិការទាំងស្រុង ពុំអាចបំពេញភារកិច្ចពលកម្ម ត្រូវឧបត្ថម្ភរហូត ។
- ក្នុងករណីគ្មានឪពុក ឬ ម្តាយ ហើយគ្មានទីពឹង ត្រូវបញ្ជូលទៅរស់នៅក្នុងមណ្ឌលកុមារកំព្រារបស់រដ្ឋ ហើយត្រូវទទួលរបបឧបត្ថម្ភរបស់មណ្ឌលកុមារកំព្រានោះ ។

ចំពោះកូននិវត្តជន និង ជនទុព្វលភាពពលកម្ម ត្រូវអនុវត្តតាមចំណុចខាងលើនេះដែរ ។

ខ - មរណៈភាពដោយគ្រោះថ្នាក់ការងារ ឬ បេសកកម្ម :

ខ១ - កម្មាភិបាល បុគ្គលិក កម្មករ ទទួលមរណៈភាពដោយគ្រោះថ្នាក់ការងារ ឬ ដោយបេសកកម្ម ក្នុងពេលបំពេញការងារប្រចាំ ឬ ប្រយុទ្ធការពារ រដ្ឋឧបត្ថម្ភប្រាក់ចំនួន ២.០០០ រៀល សំរាប់ធ្វើបុណ្យតាមប្រពៃណី ។

ខ២ - គ្រួសារសព ត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើក ស្មើនឹងប្រាក់បៀវត្សរ៍ប្រចាំខែ ដោយគិតប្រាក់គោល ប្រាក់បំណាច់គ្រួសារ និង ប្រាក់ឧបត្ថម្ភផ្សេងៗចំនួន ៨ ខែ ។

១៣- ចំពោះកូនឈ្នួល ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្នាក់ៗ ៧០ រៀលក្នុងមួយខែ និង មានសិទ្ធិទិញអង្ករ ១៥ គ.ក្រ រៀងរាល់ខែ តាមតម្លៃផ្គត់ផ្គង់របស់រដ្ឋ ព្រមទាំងមានសិទ្ធិទិញរបបផ្គត់ផ្គង់ផ្សេងៗ ដូចកូនកម្មាភិបាល បុគ្គលិក កម្មករដែលកំពុងបំពេញការងារនៅដែរ ក្រោមលក្ខខណ្ឌដូចតទៅ :

- រហូតអាយុ ១៥ ឆ្នាំ
- ចាប់ពីអាយុ ១៥ ឆ្នាំឡើងទៅ រហូតដល់ឈប់រៀន បើពុំកំពុងបន្តការសិក្សា ហើយគ្មានទទួលអាហារូបករណ៍ ។
- បើពិការ ខ្វាក់ ខ្វិន បាត់បង់សមត្ថភាពពលកម្ម ត្រូវឧបត្ថម្ភរៀងរហូត ។

ក្នុងករណីគ្មានឪពុក ឬ ម្តាយ ហើយគ្មានទីពឹង ត្រូវបញ្ជូនទៅរស់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះរបស់រដ្ឋ ហើយត្រូវទទួលរបបឧបត្ថម្ភរបស់មជ្ឈមណ្ឌលសង្គ្រោះនោះ ។

**ប្រការ ៦ :** - ករណីជួបការលំបាក :

កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម បានជួបប្រទះការលំបាកខ្លាំង ដូចជាសមាជិកគ្រួសារផ្ទាល់ត្រូវស្លាប់ រដ្ឋនឹងឧបត្ថម្ភប្រាក់ចំនួន ១.០០០ រៀល ។

**ប្រការ ៧ :** ដើម្បីអនុវត្តរបបគោលនយោបាយនេះ ក្រសួងយុទ្ធជនពិការ-សង្គមកិច្ច ក្រសួងពាណិជ្ជកម្ម និង ក្រសួងសុខាភិបាល ត្រូវចេញសារាចរណែនាំអនុវត្តអោយមានប្រសិទ្ធភាព ។

**ប្រការ ៨ :** សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ០១ សសរ-៨៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៨៣ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ-សង្គមកិច្ច ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ ក្រសួងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ប្រធានធនាគារជាតិនៃប្រជាជនកម្ពុជា រដ្ឋមន្ត្រីបណ្តាក្រសួង និង ស្ថាប័នមានការពាក់ព័ន្ធ និង គណៈកម្មាធិការប្រជាជនបដិវត្តន៍គ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន

ហត្ថលេខា និង ត្រា : ជា សុទ្ធ

កន្លែងទទួល :
- ខុទ្ទកាល័យមជ្ឈឹមបក្ស
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
"ដើម្បីជ្រាបជាពត៌មាន"
- ក្រសួងយុទ្ធជនពិការ-សង្គមកិច្ច
"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

លេខ : ១៧១៤ យ.ស. បក .
បានចម្លងតាមច្បាប់ដើមត្រឹមត្រូវហើយ
ភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៨៨
ជ. រដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ-សង្គមកិច្ច
អនុរដ្ឋមន្ត្រី